**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង

## ស្តីពី

## ការពន្យារពេលរៀបចំព្រឹត្តិការណ៍ជិះកង់ ដើម្បីអបអរសាទរទិវាយុវជនអន្តរជាតិឆ្នាំ២០២២ ក្រោមប្រធានបទ "ជិះកង់ដើម្បីការងារសមរម្យ និងបរិយាបន្នសម្រាប់យុវជនមានពិការភាព"

យោងសេចក្តីជូនដំណឹងលេខ ០៣០/២២ ក.ប/ស.ជ.ណ.ព.ទ.ក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២២ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីការរៀបចំព្រឹត្តិការណ៍ជិះកង់ ដើម្បីអបអរសាទរទិវាយុវជនអន្តរជាតិឆ្នាំ២០២២ ក្រោមប្រធានបទ "ជិះកង់ដើម្បីការងារសមរម្យ និងបរិយាបន្នសម្រាប់យុវជនមានពិការភាព" ដែលនឹងគ្រោងនៅថ្ងៃទី៦ ខែសីហា ឆ្នាំ២០២២ ខាងមុខនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកិត្តិយសសូមគោរពជម្រាបជូន ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី សាធារណជន ក្រសួងស្ថាប័ន វិស័យឯកជន និងដៃគូអភិវឌ្ឍន៍នានា ជ្រាបថា ដោយមានការសំណូមពររបស់សាធារណជនជាច្រើន រួមទាំងក្រសួងស្ថាប័ន វិស័យឯកជន ដៃគូអភិវឌ្ឍន៍ និងក្រុមអ្នកចូលចិត្តជិះកង់មួយចំនួនធំ បានស្នើសុំមកក្រសួងធ្វើការពន្យារពេលបន្ថែម ដើម្បីផ្តល់ឱកាសឱ្យសមាជិករបស់ខ្លួនបានចូលរួមច្រើនជាងនេះ ក្រសួងសូមធ្វើការលើកពេលការរៀបចំព្រឹត្តិការណ៍ជិះកង់ដើម្បីអបអរសាទរទិវាយុវជនអន្តរជាតិឆ្នាំ២០២២ ពីថ្ងៃទី៦ ខែសីហា ឆ្នាំ២០២២ ទៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០២២ វិញ ដោយរក្សាកម្មវិធី និងតម្រាយផ្លូវនៅដដែល។

ព័ត៌មានលម្អិត និងការចុះឈ្មោះចូលរួម សូមទំនាក់ទំនងមកកាន់ក្រុមការងារសម្របសម្រួលកម្មវិធីតាមរយៈលេខទូរសព្ទ ០១៧ ៧៤៧ ៧៧៣/០១៧ ៣៦៣ ៩៣៦/០១២ ៣០៦ ៨៥៥។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី សាធារណជន ក្រសួងស្ថាប័ន វិស័យឯកជន និងដៃគូអភិវឌ្ឍន៍នានា មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃ ៣រ៉ោច ៦កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ៣ ខែសីហា ឆ្នាំ២០២២

ចម្លងជូន៖

- រដ្ឋបាលរាជធានីភ្នំពេញ
- អង្គភាពពាក់ព័ន្ធ
  "ដើម្បីផ្សព្វផ្សាយ និងសហការ"
- ឯកសារ-កាលប្បវត្តិ